# ឱកាសទទួលបានមូលនិធិ
# ដំឡើងស្នាដៃ

សិល្បៈខ្មែរអមតៈ

សិល្បៈខ្មែរអមតៈ កំពុងស្វែងរកសិល្បករដែលមានចំណាប់អារម្មណ៍ក្នុងការបង្ហាញស្នាដៃសម្តែងរបស់ខ្លួនក្នុងកម្មវិធីរដូវវប្បធម៌ឆ្នាំ២០២២ក្រោមប្រធានបទ **«ទង្វើថ្ងៃនេះ ផលតបស្នងថ្ងៃស្អែក»** ខាងមុខនេះចំនួន ៤ស្នាដៃ (ស្នាដៃសម្តែងផ្ទាល់ចំនួន២ និងស្នាដៃបែបឌីជីថលចំនួន២)។

## គោលគំនិតនៃកម្មវិធីរដូវវប្បធម៌ឆ្នាំ២០២២

រាល់ទង្វើ សុទ្ធតែមានផលតបស្នង។ ជារួមមក រាល់ជម្រើស ដែលអ្នកជ្រើសរើសនៅថ្ងៃនេះនឹងបង្កើតឱ្យមានតថភាពនៃជីវិត ពោលគឺទាំងពេលបច្ចុប្បន្ន និងពេលអនាគតសម្រាប់អ្នកជំនាន់ក្រោយ។

សម្រាប់កម្មវិធីរដូវវប្បធម៌ក្នុងឆ្នាំ២០២២ យើងសូមអញ្ជើញសិល្បករនិងទស្សនិកជន ចូលរួមជាមួយយើងក្នុងការឈ្វេងយល់ និងឆ្លុះបញ្ចាំងពីទង្វើដែលយើងកំពុងប្រព្រឹត្តក្នុងថ្ងៃនេះដែលនឹងជះឥទ្ធិពលដល់ថ្ងៃស្អែក។ ទង្វើទាំងនោះអាចសាមញ្ញៗដូចជា ការជជែកលេងជាមួយម្តាយរបស់អ្នកមុនពេលចូលគេង ឬជ្រើសរើសជិះម៉ូតូឌុបទាំងខ្លួនមានអាការៈផ្តាសាយនិងអត់ពាក់មួកសុវត្ថិភាព។ ហើយទង្វើទាំងនោះក៏អាចក្នុង កម្រិតថ្នាក់ជាតិដូចជា ការអភិវឌ្ឍទីក្រុងដោយការលុបបឹង អភិរក្សអគារចាស់ៗ ការដាំដើមឈើ ឬការស្តារហេដ្ឋារចនាសម្ព័ន្ធ ជាដើម។ ទង្វើទាំងនេះ មិនថាតូច មិនថាធំ សុទ្ធតែមានផលប៉ះពាល់។

កម្មវិធីរដូវវប្បធម៌ឆ្នាំ២០២២ នឹងអញ្ជើញអ្នកទាំងអស់គ្នាឱ្យចូលរួមប្រមើលមើលអនាគតនៃប្រទេសកម្ពុជាតាមរយៈការគិតបែបស៊ីជម្រៅពីជម្រើសរាប់លានដែលអ្នកនិងសង្គមជាតិទាំងមូលបានបង្កើតរាល់ថ្ងៃ។

សំណួរដែលអ្នកទាំងអស់គ្នានឹងចូលរួមគិតរួមមានៈ

- ក្នុងបរិបទប្រទេសកម្ពុជានាពេលបច្ចុប្បន្ន តើយើងគិតថាអនាគតនៃប្រទេសកម្ពុជាទៅថ្ងៃមុខនឹងវិវត្តទៅជាយ៉ាងណា ទាំងផ្នែកសង្គម (គោល)នយោបាយ បរិស្ថាន និងការប្រើប្រាស់ទឹកន្លែង? តើជម្រើសបែបណា? អ្នកណាជាអ្នកបង្កើតជម្រើសទាំងនោះ ហើយនឹងនាំឱ្យមានផលប៉ះពាល់យ៉ាងដូចម្តេចទៅលើអនាគត? តើ "ពេលបច្ចុប្បន្ន" នឹងដើរតួយ៉ាងសកម្មក្នុងអនាគតយ៉ាងដូចម្តេច? តើអ្នកគិតថា រាល់ទង្វើរបស់អ្នកនឹងមានផលប៉ះពាល់អ្វីខ្លះ? តើអ្នកពិតជាអាចប៉ាន់ស្មានពីផលប៉ះពាល់នៃទង្វើរបស់អ្នកទេ?
- តើទង្វើរបស់អ្នក ជាមួយមនុស្សជុំវិញខ្លួនដូចជា មិត្តភក្តិ គ្រួសារ មិត្តរួមការងារ អ្នកជិតខាង ជាដើម នឹងអាចផ្លាស់ប្តូរអនាគតយ៉ាងដូចម្តេច? បើអ្នកស្រមៃក្នុងរយៈពេល៣០វិនាទី ៣០នាទី ១ឆ្នាំ ១០ឆ្នាំ រឺ ២០០ឆ្នាំពីពេលឥឡូវ?

ផ្តល់មូលនិធិដោយៈ COMMONSENSEFUND

## លក្ខន្តិកៈចូលរួម

- មានសញ្ជាតិកម្ពុជា
- អាចជាស្នាដៃទោល ឬក្រុម (មានសមាជិកមិនលើសផនាក់)
- ជាស្នាដៃសិល្បៈទស្សនីយភាព (ល្ខោន របាំ តន្ត្រី -ល-) ឬស្នាដៃសិល្បៈចម្រុះ (របាំនិងកុន, គំនូរនិងតន្ត្រី -ល-)
- ស្នាដៃទាំងនេះអាចជាស្នាដៃសម្តែងផ្ទាល់លើឆាក (២ស្នាដៃ) និងបែបឌីជីថល (២ស្នាដៃ)
- ជាស្នាដៃបង្កើតថ្មីដែលកំពុងអភិវឌ្ឍបន្ថែម ឬជាស្នាដៃត្រៀមបង្កើតថ្មី
- ស្នាដៃត្រូវនឹងគោលគំនិតនៃកម្មវិធីរដូវវប្បធម៌ឆ្នាំ២០២២ ហើយត្រូវមានរយៈពេលសម្តែង ៣០ទៅ ៤៥ នាទី។ សិល្បករត្រូវមានពេលចូលរួមកម្មវិធីរដូវវប្បធម៌ក្នុងខែមករានិងកុម្ភៈ ឆ្នាំ២០២២ (តម្រូវឲ្យមានការសម្តែង២ដង ព័ត៌មានបន្ថែមនឹងផ្តល់ជូនបន្ទាប់ទៀត)

ព័ត៌មានបន្ថែមសូមទាក់ទងលេខទូរស័ព្ទ ឬ Telegram 0៨៦ ៨៩៥ ៥៥៦ អំឡុងម៉ោងធ្វើការ ច័ន្ទ-សុក្រ ម៉ោង ៩:00-១២:00 / ២:00-៥:00 ឬអ៊ីមែល chandaly@cambodianlivingarts.org

ផ្តល់មូលនិធិដោយ៖ COMMONSENSEFUND